## នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
## អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

### ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ/អ.ជ.ត.ក (១៨)

ភាគីដាក់ឯកសារ: ក្រុមមេធាវីការពារក្ដីលោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១២

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Nov-2012, 14:14
CMS/CFO: Sann Rada

### <u>ចំណាត់ថ្នាក់ឯកសារ</u>

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សារណាឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ផ្សេងៗរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១

---

<u>ដាក់ដោយ</u>៖

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ
Michiel PESTMAN
Victor KOPPE
Andrew IANUZZI
Jasper PAUW
ព្រុំ ផល្លា
Joshua ROSESWEIG

**<u>ផ្ញើជូន</u>៖**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា**

**លោកស្រី ជា លាង**

**លោក Andrew CAYLEY**

**សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**PICH Ang**
**Elisabeth SIMONNEAU-FORT**

## I. សេចក្ដីផ្ដើម

១. មេធាវីការពារក្ដីជនជាប់ចោទ នួន ជា ("ក្រុមមេធាវីការពារក្ដី") តទៅនេះសូមដាក់សារណាឆ្លើយតប **ទៅនឹងបណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង 00២/0១** ("បណ្ដឹងសារទុក្ខ")[1]។ សម្រាប់មូលហេតុនានាដែលលើកឡើងដូចខាងក្រោម មេធាវីការពារក្ដីស្នើឱ្យពិចារណាថា (i)បណ្ដឹងសារទុក្ខភ្លាមៗប្រឆាំងនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ("សេចក្ដីសម្រេច")[2] មិនអាចទទួលយកបាន និង(ii) ឬត្រូវតែបដិសេធចោល។ ចំពោះមូលហេតុនៃការពន្លឿនកិច្ចនិតីវិធី មេធាវីការពារក្ដីនឹងមិនឆ្លើយតបទៅនឹងជំហរ និងអំណះអំណាងទាំងអស់ដែលដាក់ដោយសហព្រះរាជអាជ្ញា ប៉ុន្តែវាមិនត្រូវបានបកស្រាយថា ជាការគាំទ្រដល់ជំហរ និងអំណះអំណាងទាំងនេះឡើយ ។

## II. ប្រវត្តិនីតិវិធី

២. មេធាវីការពារក្ដីយោងកថាខណ្ឌ៤ ដល់៩ នៃបណ្ដឹងសារទុក្ខភ្លាមៗ សម្រាប់ការពិនិត្យឡើងវិញនៃប្រវត្តិនិតីវិធី ។

## III. បណ្ដឹងសារទុក្ខភ្លាមៗនេះមិនអាចទទួលយកបានទេ

៣. បណ្ដឹងសារទុក្ខភ្លាមៗនេះមិនអាចទទួលយកបាន ដោយសារលក្ខខណ្ឌតម្រូវដែលពាក់ព័ន្ធនៃវិធាន ១០៤.៤(ក) មិនបានបំពេញ: សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង "មិនមានអនុភាពបញ្ចប់និតីវិធីឡើយ"។ សហព្រះរាជអាជ្ញាប៉ុនប៉ងធ្វើឱ្យអង្គជំនុំជម្រះតុលាការកំពូលជឿថាការបន្តកិច្ចដំណើរ

---

[1] ឯកសារ E- 163/5/1/1 "បណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងករណី00២/0១ ជាមួយឧបសម្ព័ន្ធ I និងឧបសម្ព័ន្ធ II" ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១២ ERN 00859078-00859107 ("បណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា")។

[2] ឯកសារ E- 163/5 "ការជូនដំណឹងស្ដីពីសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះនៅក្នុងករណី00២/0១ (E163) និងពេលវេលាកំណត់នៃការដាក់សេចក្ដីសន្និដ្ឋានបញ្ចប់នៃការពិភាក្សាដេញដោលពាក់ព័ន្ធច្បាប់ជាធរមាន" ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ERN 00850036-00850037 (ការជូនដំណឹងអំពីសេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជ អាជ្ញា")។

ការនិតីវិធីទាក់ទិននឹងមន្ទីរស-២១ និងការសម្លាប់ដែលត្រូវបានសន្មតនៅស្រុកកំពង់ត្រឡាចលើ (ស្រុក ១២) គឺមិនទំនង ។ សហព្រះរាជអាជ្ញាអះអាងថា: "អនាគតនៃការជំនុំជម្រះដែលត្រូវធ្វើតទៅមុខទៀត [...] គឺនៅឆ្ងាយណាស់[3] ។ សហព្រះរាជអាជ្ញាពិភាក្សាលើ "ហានិភ័យជាដុំកំភួនដែលថាជនជាប់ចោទនឹងមិនត្រូវបានទទួលការជំនុំជម្រះបន្ថែម"[4] និងបានលើកឡើងថាការមិនដាក់បញ្ចូល [...] នឹងនាំឱ្យមានស្ថានការមួយដែលជនជាប់ចោទ [...] ប្រហែលជាមិនត្រូវបានជំនុំជម្រះចំពោះឧក្រិដ្ឋកម្មសំខាន់បំផុត ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងពួកគេឡើយ"[5]។

៤. ខណៈដែលមេធាវីការពារក្តីចង់ទទួលយកអង្គហេតុដែលថា សហព្រះរាជអាជ្ញាភ័យខ្លាចថាលក្ខខណ្ឌនានាដែលស្នើឡើងចំពោះសំណុំរឿង០០២/០១ នឹងមិនត្រូវបានជំនុំជម្រះ នោះការភ័យខ្លាចនេះមិនផ្លាស់ប្តូរសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ឱ្យទៅជាសេចក្តីសម្រេចដែលមានអនុភាពបញ្ចប់ដំណើរការនិតីវិធីដែរ។ អង្គជំនុំជម្រះសាលាដំបូងមិនត្រឹមតែរក្សានូវឆន្ទានុសិទ្ធិពេញលេញទាក់ទិននឹងសេចក្តីសម្រេចថា តើត្រូវបន្ត ឬមិនបន្តការជំនុំជម្រះលើអង្គហេតុបន្ថែម តាមពិតអង្គជំនុំជម្រះសាលាដំបូងបានប្រកាសរួចហើយ (ហើយគេអាចនិយាយៈ ហេតុដូច្នេះអង្គជំនុំជម្រះបានប្តេជ្ញាចិត្ត)ថាអង្គជំនុំជម្រះមានចេតនាឱ្យការជំនុំជម្រះលើអង្គហេតុបន្ថែមកើតឡើង។ នៅក្នុងអនុស្សរណៈដែលអង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួនអាចពិចារណាពង្រីកសមហេតុផលនូវវិសាលភាពនៃសំណុំរឿង ០០២/០១ ហើយអង្គជំនុំជម្រះសាលាដំបូងក៏បានលើកឡើងថា នេះគឺជាចេតនារបស់អង្គជំនុំជម្រះសាលាដំបូង [...] ចាប់ផ្តើមសំណុំរឿង០០២/០២ ភ្លាមៗបន្ទាប់ពីការបញ្ចប់សវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១"[6]។ ពុំមានហេតុផលថាហេតុអ្វីការភ័យរបស់សហព្រះរាជអាជ្ញាដែលថាការជំនុំជម្រះបន្ថែមមិនអាចធ្វើបាន "នឹងយកឈ្នះ" ជំហររបស់អង្គជំនុំជម្រះសាលាដំបូងដែលថា អង្គជំនុំជម្រះមានចេតនាពេញលេញក្នុងការដំណើរការជំនុំជម្រះបន្ថែម ហើយបើនិយាយក្នុងន័យម្យ៉ាងទៀត

---

[3] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២ ។

[4] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣៦ ។

[5] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣៧ ។

[6] ឯកសារ **E- 128** "ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់នៅក្នុងសំណុំរឿង០០២/០១ និងដើម្បីអនុវត្តវិធានការបន្ថែមដើម្បីលើកកំពស់ប្រសិទ្ធិភាពនៃសវនាការ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១២ ERN 00831321-00831326 នៅកថាខណ្ឌ១។

ពុំមានហេតុផលណាដើម្បីលើកឡើងថា សេចក្តីសម្រេចនេះបញ្ចប់កិច្ចដំណើរការនិតីវិធី ឬមានអនុភាពបញ្ចប់កិច្ចដំណើរការនិតីវិធីឡើយ៖ កិច្ចដំណើរការនិតីវិធីបន្ថែមនៅក្នុងសំណុំរឿង០០២/០១ គឺពិតជាអាចធ្វើបានទាំងស្រុង និង សមហេតុផលទៀតផង។

៥. យ៉ាងហោចណាស់ សេចក្តីសម្រេចនេះមានអនុភាពផ្អាកសេចក្តីសម្រេចថា តើត្រូវជំនុំជម្រះ ឬមិនត្រូវជំនុំជម្រះអង្គហេតុនៅជុំវិញស-២១ និងស្រុក១២ ទៅពេលក្រោយ ហើយសេចក្តីសម្រេចនាថ្ងៃអនាគតនឹងត្រូវផ្អែកលើកត្តាជាច្រើន ហើយថាការវាយតម្លៃត្រឹមត្រូវអាចធ្វើបាននៅពេលវេលាមិនអាចបញ្ជាក់បាននៅថ្ងៃអនាគតតែប៉ុណ្ណោះ។ ការដែលថាការសម្រេចចុងក្រោយថា តើត្រូវបន្ត ឬបញ្ឈប់ការជំនុំជម្រះ ត្រូវតែធ្វើនៅពេលវេលាណាមួយនាថ្ងៃអនាគត ហើយការដែលថាអង្គជំនុំជម្រះសាលាដំបូងនឹងរក្សាឆន្ទានុសិទ្ធិបន្ត ឬមិនបន្តការជំនុំជម្រះនៅដំណាក់កាលក្រោយៗ ដើម្បីទប់ទល់នឹងការទទួលយកបណ្តឹងសារទុក្ខនេះ។

## IV. អង្គជំនុំជម្រះសាលាដំបូងមិនមានកំហុសលើអង្គច្បាប់ ហើយ ក៏មិនមានកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដែរ

### ក.វិសាលភាពនៃការពិនិត្យបណ្តឹងសារទុក្ខនេះ

៦. ជំហររបស់សហព្រះរាជអាជ្ញា គឺថាអង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ឬមានកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានក្នុងចំណោមបញ្ហាដទៃទៀត មិនបានអនុវត្តត្រឹមត្រូវនូវបទដ្ឋានគតិយុត្តិចំពោះការបំបែកបទចោទប្រកាន់ នៅក្នុងការបដិសេធមិនបញ្ចូលទីតាំងឧក្រិដ្ឋកម្មនៅស្រុក១២ និងស-២១[7]។ ចំពោះវិសាលភាពនៃការពិនិត្យបណ្តឹងសារទុក្ខ សហព្រះរាជអាជ្ញាកត់សម្គាល់ថាការគោរពចំពោះសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង មិនមែនជាការគោរពយ៉ាងដាច់ខាតនោះទេ ហើយនេះមិនមែនជាតម្រូវឲ្យអង្គជំនុំជម្រះតុលាកំពូលធ្វើការពិនិត្យឡើងវិញដោយពឹងផ្អែកលើអង្គហេតុ ឬអង្គច្បាប់ដែលមិនត្រឹមត្រូវនោះដែរ[8]។ មេធាវីការពារក្តីយល់ស្របជាមួយការសន្និដ្ឋាននេះលើវិសាលភាពនៃពិនិត្យបណ្តឹងសារទុក្ខ។

[7] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២១។

[8] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២៥។

### ខ. ការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា ការពិចារណាចម្បងត្រូវតែផ្តោតលើលក្ខខណ្ឌតម្រូវនៃការតំណាងសមហេតុផល (reasonable representativeness) គឺមិនត្រឹមត្រូវទេ

៧. ប៉ុន្តែការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាដែលថា អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តហួសឆន្ទានុសិទ្ធិរបស់ខ្លួន ឬ បានពឹងផ្អែកលើអង្គច្បាប់ ឬអង្គហេតុនៅក្នុងករណីនេះ គឺមិនត្រឹមត្រូវ។ មូលដ្ឋានចម្បងសម្រាប់បណ្តឹងសារទុក្ខនេះ គឺការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា"នៅក្នុងការបំបែកបទចោទ ការពិចារណាបឋម ត្រូវតែផ្តោតលើលក្ខខណ្ឌតម្រូវនៃការតំណាងសមហេតុផល **(reasonable representativeness)**[9]។

៨. សហព្រះរាជអាជ្ញាផ្អែកការអះអាងរបស់ខ្លួនទាំងស្រុងទៅលើការបកស្រាយវិធាន៨៩ស្ទួនពីរ។ វិធាននេះចែងទាំងស្រុង: "នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយអង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឱ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប"។

៩. សហព្រះរាជអាជ្ញាបានផ្តោតជាសំខាន់ទៅលើពាក្យ"ផលប្រយោជន៍យុត្តិធម៌" នៅក្នុងវិធាន៨៩ស្ទួនពីរ និងភាពស្មុគស្មាញនៅជុំវិញអត្ថន័យនៃទស្សនទាននេះ។ អនុលោមតាមសហព្រះរាជអាជ្ញា ដោយសារ "ពុំមានការណែនាំនៅក្នុងវិធាននេះ ច្បាប់បង្កើត អវតក ឬ នៅក្នុងក្រមនីតិព្រហ្មទណ្ឌកម្ពុជាទាក់ទិននឹងធាតុផ្សំដែលត្រូវពិចារណាអំពី "ផលប្រយោជន៍យុត្តិធម៌" នៅក្នុងបរិបទនៃការបំបែកកិច្ចនីតិវិធី" ដូច្នេះជាការត្រឹមត្រូវដើម្បីងាកទៅរកទម្លាប់អនុវត្តអន្តរជាតិ អនុលោមតាមមាត្រា៣៣ថ្មីនៃច្បាប់អវតក[10]។

១០. ជំហរនេះមិនអាចឱ្យជឿបាន។ ជាបឋម នៅមុនងាកទៅរកការណែនាំណាមួយសម្រាប់ការបកស្រាយអត្ថន័យនៃពាក្យ "ផលប្រយោជន៍យុត្តិធម៌" គោលបំណង និងសារតានៃវិធាន៨៩ស្ទួនពីរទាំងមូលត្រូវតែបានពិចារណា។ វិធាន៨៩ស្ទួនពីរ គឺជាឧបករណ៍សម្រាប់ការគ្រប់គ្រងការជំនុំជម្រះដោយប្រសិទ្ធិភាព ហើយវាច្បាស់ណាស់ថា វិធាននេះមានបំណងផ្តល់ឱ្យអង្គជំនុំជម្រះសាលាដំបូងនូវឆន្ទា

---

[9] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣១-៣៥។

[10] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣១។

នុសិទ្ធិយ៉ាងទូលំទូលាយ[11]។ មូលហេតុតែមួយគត់គឺថាឆន្ទានុសិទ្ធិនេះត្រូវបានបង្កើតឡើងក្នុងន័យទូលំទូលាយពេក ហើយហេតុដូច្នេះ វិធាននេះមិនមានអ្វីក្រៅតែពីយន្តការនៃការគ្រប់គ្រងជំនុំជម្រះនោះឡើយ។ វិធាននេះមិនបានប្រមើលទុកនូវវិធានការដ៏គំហុកបែបនេះទេ ដូចជាការមិនបន្តការចោទប្រកាន់។ បើតាមវិធាននេះ ករណីទាំងអស់នឹងត្រូវយកមកជំនុំជម្រះ វាគ្រាន់តែជាលំដាប់លំដោយនៃរឿងក្ដីដែលត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងប៉ុណ្ណោះ។ តាមន័យនេះ បើពិចារណាពីឆន្ទានុសិទ្ធិដ៏ទូលំទូលាយនេះ នោះវាច្បាស់ណាស់ថា"ផលប្រយោជន៍យុត្តិធម៌"អាចមានន័យអ្វីមួយដែលអង្គជំនុំជម្រះសាលាដំបូងយល់(សមហេតុសមផល) ថាវាមានន័យបែបហ្នឹង។ វាប្រាកដណាស់ថាអង្គជំនុំជម្រះសាលាដំបូង អាចពិចារណាកាលៈទេសៈជាច្រើននៅពេលសម្រេចលើការបំបែកបទចោទដូចជាតម្រូវការពន្លឿនកិច្ចនីតិវិធី ស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងផលប្រយោជន៍របស់ជនរងគ្រោះ ព្រមទាំងការពិចារណាដ៏សាមញ្ញអំពីការគ្រប់គ្រងការជំនុំជម្រះ ដូចជាការប្រាថ្នាចង់បានការពិភាក្សាលើអង្គហេតុដែលមានទំនាក់ទំនងយ៉ាងជិតស្និទក្នុងពេលវេលាជាក់លាក់ និងដ៏ចង្អៀតនេះ។ ដើម្បីឱ្យប្រាកដថា ពុំមានអ្វីមករារាំងអង្គជំនុំជម្រះសាលាដំបូងមិនឱ្យពិចារណាអំពី "ការតំណាងនៃការចោទប្រកាន់ (representativeness of the charges) នៅពេលសម្រេចបំបែកផ្នែកនៃសំណុំរឿង។ ប៉ុន្តែក្ដីបារម្ភនេះ មិនមែនជាក្ដីបារម្ភតែមួយដែលមានប្រៀបលើការព្រួយបារម្ភសមហេតុផលដទៃទៀតនោះទេ ("ការពិចារណាបឋម") ដូចដែលសហព្រះរាជអាជ្ញាអាចមាន ។

១១. អាស្រ័យហេតុនេះឆន្ទានុសិទ្ធិទូលំទូលាយដែលបានផ្ដល់ឱ្យអង្គជំនុំជម្រះសាលាដំបូងមានន័យថា ពុំចាំបាច់ការណែនាំអំពីទម្លាប់អនុវត្តអន្តរជាតិ ដើម្បីជាជំនួយដល់ការបកស្រាយអត្ថន័យនៃពាក្យ "ផលប្រយោជន៍យុត្តិធម៌"ឡើយ។ វាពិតណាស់ថា "ផលប្រយោជន៍យុត្តិធម៌" មានន័យទូលំទូលាយមែន ហើយថាន័យទូលំទូលាយនេះ មិនមែនជាបញ្ហានៅក្នុងបរិបទនៃវិធាន៨៩ស្ទួនពីរឡើយ។ និយាយក្នុង

[11] ដូចដែលអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងបានកត់សម្គាល់ ការលើកឡើងបែបនេះត្រូវបានបង្ហាញដោយអង្គហេតុដែលថា វិធាននេះមិនប្រមើលទុកជាមុនអំពីលទ្ធភាពនៃការប្ដឹងសារទុក្ខប្រឆាំងនឹងសេចក្ដីសម្រេចបែបនេះទេ។

ន័យម្យ៉ាងទៀត ពុំត្រូវការងាកទៅរកទម្លាប់អនុវត្តអន្តរជាតិឡើយ ហើយឆន្ទានុសិទ្ធិទូលំទូលាយរបស់អង្គជំនុំជម្រះសាលាដំបូងអនុលោមតាមវិធាននេះ គឺមានន័យច្បាស់[12]។

*វិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY មិនអាចផ្តល់ជាការណែនាំបានឡើយ*

១២. សំខាន់បំផុតបើសិនជាគេទទួលយកជំហររបស់សហព្រះរាជអាជ្ញាដែលថា ត្រូវតែស្វែងរកការណែនាំទម្លាប់អនុវត្តនៅកម្រិតអន្តរជាតិសម្រាប់ការបកស្រាយអត្ថន័យនៃពាក្យ "ផលប្រយោជន៍យុត្តិធម៌" នោះវាច្បាស់ណាស់ថា ដោយសារហេតុផលជាច្រើន ការណែនាំបែបនេះមិនអាចរកបាន (និងមិនគួរស្វែងរក) នៅក្នុងវិធាន៧៣ស្ទួន(ឃ)នៃវិធានស្តីពីនិតីវិធី និងភស្តុតាងរបស់តុលាការ ICTY ឡើយ។

១៣. នេះគឺជាការពិត ដោយសារជាបឋមវិធាន៧៣ស្ទួន(ឃ) និងវិធាន៨៩ស្ទួន មានគោលបំណង និងការអនុវត្តខុសជាមូលដ្ឋាន។ ការអនុវត្តវិធាន៧៣ស្ទួន(ឃ) នាំឲ្យបញ្ចប់ពិតៗនៃកិច្ចដំណើរការនិតីវិធីនៃការចោទប្រកាន់នានាដែលអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY សម្រេចមិនជំនុំជម្រះដែលចំណុចនេះគឺខុសគ្នាយ៉ាងសំខាន់ជាមួយវិធាន៨៩ស្ទួនរបស់ អវតក ដែលមិនអាចលើកលែង ឬបញ្ចប់ការចោទ

---

[12] មូលហេតុផ្សេងដែលនឹងហុចលទ្ធផលដូចគ្នា គឺគ្រាន់តែពិនិត្យមើលឲ្យបានស៊ីជម្រៅនូវអត្ថន័យពិតប្រាកដនៃវិធាន៨៩ស្ទួនពីរបានហើយ។ សហព្រះរាជអាជ្ញាចាត់ទុកផ្នែក "ផលប្រយោជន៍យុត្តិធម៌" នៃវិធាន៨៩ស្ទួនពីរ ជាការណែនាំដែលមានឥទ្ធិពលមួយដែលហ៊ុំព័ទ្ធវិធាននេះទាំងមូល ហើយដូច្នេះបានស្នើថា សេចក្តីសម្រេចបំបែកកិច្ចដំណើរការនិតីវិធីរបស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែបានចង្អុលផ្លូវដោយគោលការណ៍អរូបិយមួយ ដែលនោះគឺ "ផលប្រយោជន៍យុត្តិធម៌)។ ប៉ុន្តែ វាជាការសំខាន់ក្នុងការងាកទៅរកការពិនិត្យអត្ថន័យច្បាស់ៗរបស់វិធាន៨៩ស្ទួនពីរៈ វិធាននេះមិនបាននិយាយអំពី"ផលប្រយោជន៍យុត្តិធម៌" នៅក្នុងន័យទូទៅណាមួយឡើយ ប៉ុន្តែវានិយាយជាក់លាក់ពី"ផលប្រយោជន៍យុត្តិធម៌"ដែលផ្តល់អំណាច (តម្រូវ) ឲ្យមានការបំបែកកិច្ចនិតីវិធីយ៉ាង ច្បាស់។ នៅពេលផលប្រយោជន៍យុត្តិធម៌តម្រូវ អង្គជំនុំជម្រះអាច [...] អាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធី")។ និយាយម្យ៉ាងទៀត ដើម្បីឲ្យសេចក្តីសម្រេចរបស់អង្គជំនុំ ជម្រះសាលាដំបូងផ្អែកតាមវិធាន៨៩ស្ទួនពីរ គេត្រូវតែអាចចកំណត់ "ផលប្រយោជន៍យុត្តិធម៌" ជាក់លាក់ដែលតម្រូវឲ្យមានការបំបែកកិច្ចដំណើរការនិតី។ ផលប្រយោជន៍យុត្តិធម៌ដែលតម្រូវឲ្យមានការបំបែកកិច្ចដំណើរការនិតីវិធីត្រូវតែជាការពន្លឿនការជំនុំជម្រះយ៉ាងច្បាស់ និងបំណងប្រាថ្នាឲ្យមានការវិនិច្ឆ័យទោសប្រឆាំងនឹងជនជាប់ចោទដែលចាស់ជរាហើយចំពោះ "ការតំណាងនៃការចោទប្រកាន់វិញ" គឺច្បាស់ណាស់មិនមែនជាផលប្រយោជន៍យុត្តិធម៌ដែល"តម្រូវ" ឲ្យមានការបំបែកកិច្ចដំណើរការនិតីវិធីទេ។ និយាយម្យ៉ាងទៀត ពុំតម្រូវឲ្យងាកទៅរកការណែនាំពីទម្លាប់អនុវត្តអន្តរជាតិលើបញ្ហានៃការតំណាងនៃការចោទប្រកាន់ឡើយ (representativeness of charges)

ប្រកាន់នានាដែលនៅសេសសល់ឡើយ[13]។ និយាយម្យ៉ាងទៀតវិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY គឺជាឧបករណ៍ដើម្បីដាក់កម្រិតការលើកលែងការចោទប្រកាន់ តែវិធាន៨៩ស្ទួនរបស់ អវតក វិញ គឺគ្រាន់តែឧបករណ៍សម្រាប់ការកំណត់កាលបរិច្ឆេទ ដែលមិនបានប្រមើល ឬចែងពីការលើកលែងការចោទប្រកាន់ឡើយ។

១៤. មូលហេតុដែលថាភាពខុសគ្នារវាងវិធានទាំងពីរនេះ គឺសំខាន់ជាសារវ័ន្តនៅក្នុងបរិបទនៃបណ្តឹងសារទុក្ខនេះ ដោយសារតែវាអាចដឹងបាននៅក្នុងរចនាសម្ព័ន្ធច្បាប់របស់តុលាការ ICTY ហើយវិធាន៧៣ស្ទួន(ឃ)ចែងថា បទចោទដែលនៅសេសសល់ត្រូវតែជាតំណាងសមហេតុផលនៃឧក្រិដ្ឋកម្មដែលបានចោទ ដោយសារតែការចោទប្រកាន់បន្ថែម នឹងមិនត្រូវយកមកជំនុំជម្រះដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ឡើយ។ និយាយម្យ៉ាងទៀត ការចោទប្រកាន់ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីទំហំតូចនៃរឿងក្តីទាំងមូល។ អាស្រ័យហេតុនេះការតំណាង(representativeness) គឺជាការពិចារណាលើសលុបនៅក្នុងប្រព័ន្ធនោះ។ ប៉ុន្តែវាខុសគ្នាទាំងស្រុងទៅនឹងស្ថានភាពនៅ អវតក ជាមួយនឹងវិធាន៨៩ស្ទួនពីរ នៅក្នុងករណីមានរឿងក្តីបន្ថែមត្រូវបានសន្មតថាត្រូវយកមកជំនុំជម្រះ នៅអវតក យើងគ្រាន់តែដោះស្រាយការជំនុំជម្រះធំៗដែលចែកចេញជាដំណាក់កាលៗតាមរយៈការអនុវត្តវិធាននេះ[14]។ អាស្រ័យហេតុនេះ “ការតំណាងនៃការចោទប្រកាន់” (representativeness of charges) គឺពិតជាមិនមានតួនាទីនៅក្នុងការបកស្រាយវិធាន៨៩ស្ទួនពីរឡើយ។ វិធាន៧៣ស្ទួន(ឃ) មិនអាចយកមកប្រើប្រាស់ដើម្បីបកស្រាយវិធាន៨៩ស្ទួនពីរ ឬជាការណែនាំដល់អង្គជំនុំជម្រះសាលាដំបូងនៅពេលអនុវត្តវិធាននេះឡើយ ហើយវិធាននេះពិតជាមិនអាចយកមកផ្អែកនៅដំណាក់កាលបណ្តឹងសារទុក្ខដើម្បីគាំទ្រ

---

[13] វិធានផ្ទៃក្នុងមានតែណែនាំយ៉ាងមានប្រសិទ្ធិភាពឲ្យអង្គជំនុំជម្រះសាលាដំបូង ជំនុំជម្រះបទចោទនៅដំណាក់កាលក្រោយៗទៀត៖ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយ ដែលអង្គជំនុំជម្រះយល់ឃើញថាសមស្រប (បញ្ជាក់បន្ថែម)។

[14] ការដែលថាសហព្រះរាជអាជ្ញាចោទប្រកាន់ថា ការចោទប្រកាន់បន្ថែមមិនទំនងជាមិនមានទេនៅក្នុងករណីនេះ គឺមិនពាក់ព័ន្ធទេនៅពេលងាកចេញពីចេតនាពិតៗនៅពីក្រោយវិធាននេះ ដោយសារតែសហព្រះរាជអាជ្ញាកំពុងតែព្យាយាមធ្វើបណ្តឹងសារទុក្ខ។ ច្បាស់ណាស់ថាវិធាននេះ រួមទាំងផ្នែក “ផលប្រយោជន៍យុត្តិធម៌របស់ខ្លួន” ត្រូវបានសរសេរឡើងដោយផ្អែកលើការសន្មតនៅក្នុងចិត្ត ហើយហេតុដូច្នេះ វិធាន៧៣ស្ទួន(ឃ) នៅ ICTY ពុំមានតួនាទីនៅក្នុងការបកស្រាយទេ បើទោះបីជាគេទទួលយកជំហររបស់សហព្រះរាជអាជ្ញាដែលថា ការចោទប្រកាន់បន្ថែមនឹងមិនទំនងជាមាននៅក្នុងករណីនេះក៏ដោយ។

ដល់ការអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ឬអង្គហេតុ ឬរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយមិនបានពិចារណាប្រព័ន្ធនៅតុលាការ ICTY ឡើយ។

១៥. តែមានមូលហេតុមួយទៀតថា ហេតុអ្វីបានជាវិធាន៧៣ស្ទួន(ឃ) មិនអាចផ្តល់ការណែនាំនៅពេលបកស្រាយវិធាន៨៩ស្ទួនពីរ អាចរកឃើញនៅក្នុងសារតារ និងប្រវត្តិនិតីបញ្ញត្តិរបស់វិធាននេះ ។ នៅពេលពិភាក្សាបញ្ហានេះ កិច្ចប្រជុំពេញអង្គពិចារណាយ៉ាងសកម្មលើការអនុវត្តវិធាននេះស្របគ្នានឹងវិធាន៧៣ស្ទួន(ឃ) ប៉ុន្តែត្រូវបានបដិសេធចោលយ៉ាងច្បាស់: ជាលទ្ធផល "កិច្ចប្រជុំពេញអង្គរបស់ អវតក នាខែកុម្ភៈ ឆ្នាំ២០១១ សម្រេចមិនចម្លងតាមវិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY នោះទេតែថែមទាំងបានអនុម័តវិធាន៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុងបច្ចុប្បន្ននេះទៅវិញ"[15]។ អនុលោមតាមអង្គជំនុំជម្រះ មូលហេតុចំពោះសេចក្តីសម្រេចនោះ គឺថាវិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY ជាវិធានការជាក់លាក់ដែលត្រូវបានបង្កើតនៅក្នុងស្ថាប័នមួយដែលខុសគ្នាឆ្ងាយពីវិធានរបស់ [អវតក][16]។ និយាយម្យ៉ាងទៀតកិច្ចប្រជុំពេញអង្គរបស់ អវតក មិនត្រឹមតែបានបដិសេធការអនុវត្តវិធានស្រដៀងគ្នាទៅនឹងវិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY នោះទេ តែថែមទាំងបានពិចារណាថារចនាសម្ព័ន្ធនៅ អវតក និងរចនាសម្ព័ន្ធនៅតុលាការ ICTY គឺមានភាពផ្ទុយគ្នាទាក់ទងនឹងប្រធានបទពិសេសមួយនេះ[17]។ ដោយពិចារណាការបដិសេធដោយមានមូលហេតុនៃវិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY ដោយអ្នក

---

[15] ឯកសារ E- 124/7 "សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ អំពីលក្ខខណ្ឌនានា របស់ដីកាសម្រេច បំបែកកិច្ចដំណើរការនិតីវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (E124/2) និង ញត្តិ និងឧបសម្ព័ន្ធពាក់ព័ន្ធ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ERN 00747737-00747742 នៅកថាខណ្ឌ5 [សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជ អាជ្ញា សុំឱ្យ ពិចារណាឡើងវិញ] ។

[16] សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យពិចារណាឡើងវិញ នៅកថាខណ្ឌ៣ ។ សូមមើលការពន្យល់បន្ថែមនៅកថាខណ្ឌ៤។

[17] បន្ថែមពីលើនេះដោយពិចារណាថា លក្ខខណ្ឌតម្រូវនៃ "ការតំណាង" វិធាន៧៣ស្ទួន(ឃ)របស់តុលាការ ICTY ជាអនុប្រយោគប្រតិបត្តិការដ៏លេចធ្លោ ដូច្នេះការសម្រេចមិនដាក់បញ្ចូលភាសាស្រដៀងគ្នានេះទៅក្នុងវិធាន៨៣ស្ទួនពីរ ត្រូវបានយល់ថាជាការបដិសេធទាំងស្រុងនៃការតំណាង ដែលជាការពិចារណាស្នូល (ឬអាចជាចំណុចសំខាន់) សម្រាប់សេចក្តីសម្រេចបំបែកកិច្ចដំណើរការនិតីវិធី។

ពង្រាងវិធានផ្ទៃក្នុង វាច្បាស់ណាស់ថាវិធាននេះមិនអាចផ្តល់ការណែនាំបានទេនៅពេលបកស្រាយវិធាន៨៩ស្ទួនពីរនោះ។

## គ. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាយ៉ាងត្រឹមត្រូវអំពីចំនួនសាក្សីដែលត្រូវបានស្នើឡើងនៅក្នុងការចេញសេចក្តីសម្រេចរបស់ខ្លួន

១៦. បណ្តឹងសារទុក្ខថែងថា "អង្គជំនុំជម្រះសាលាដំបូងមានកំហុសដែលអាចវិនិច្ឆ័យបាន នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយផ្អែកសំអាងហេតុរបស់ខ្លួនទៅលើការពិចារណាមួយដែលពុំមានការពាក់ព័ន្ធ (ចំនួនសាក្សីដែលត្រូវបានស្នើឡើង) និងការខកខានពុំបានពិចារណា និងសម្រេចឲ្យបានត្រឹមត្រូវទៅលើចំនួនសាក្សីដែលនឹងតម្រូវឲ្យមកផ្តល់សក្ខីកម្ម[18]។

១៧. តាមការអានសមហេតុផលនៃសេចក្តីសម្រេចនេះ បញ្ជាក់យ៉ាងច្បាស់ថាអង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃជាបឋមលើសាក្សីទាំងអស់ដែលត្រូវបានស្នើឡើងដោយភាគី និងបានរកបានឃើញជាបឋមថាចំនួនសាក្សីដែលនឹងត្រូវផ្តល់សក្ខីកម្ម (ដោយពិចារណាពីការតម្រូវឲ្យមានការជំនុំជម្រះដោយយុត្តិធម៌) នៅក្នុងករណីដែលបទចោទត្រូវបានពង្រីក នឹងបង្កហានិភ័យដល់ការពន្យារពេលវេលា។ ជាការត្រឹមត្រូវដែលអង្គជំនុំជម្រះសាលាដំបូងធ្វើការវាយតម្លៃបែបនេះនៅក្នុងក្របខណ្ឌសិទ្ធិរបស់ខ្លួន។

១៨. ពុំមានបទប្បញ្ញត្តិណាមួយនៅក្នុងវិធានផ្ទៃក្នុងបង្ខំឲ្យអង្គជំនុំជម្រះត្រូវតែសម្រេចជាមុន និងឲ្យបានលម្អិតពីចំនួនសាក្សីដែលនឹងត្រូវកោះហៅ និងចំណុចអ្វីដែលពួកគេនឹងផ្តល់សក្ខីកម្ម អង្គជំនុំជម្រះអាចឈានទៅរកការសម្រេច(មិន)ពង្រីកការចោទប្រកាន់។ តាមពិតការតម្រូវពេលវេលា និងកំលាំងពលកម្មដ៏ច្រើនបែបនេះ នឹងផ្ទុយពីគោលបំណងនៃវិធាន៨៩ស្ទួនពីរ ដែលជាវិធានសម្រាប់ធ្វើឲ្យប្រសើរ និងពន្លឿនដំណើរការនិតីវិធី។ ហេតុដូច្នេះការអះអាងរបស់សហព្រះរាជអាជ្ញានៅចំណុចនេះ ត្រូវតែគ្មានជោគជ័យ។

១៩. មេធាវីការពារ នួន ជា ត្រូវការបង្កើតកំណត់ត្រាលើការអះអាងដោយសហព្រះរាជអាជ្ញា នៅពេលពួកគេលើកឡើងថា "មេធាវីការពារក្តី នួន ជា បានខកខានមិនបានផ្តល់យុត្តិកម្មឲ្យបានច្បាស់លាស់ដើម្បី

---

[18] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៥៩។

គាំទ្រដល់សាក្សីដែលខ្លួនបានស្នើឡើង"[19]។ សហព្រះរាជអាជ្ញាលើកឡើងថា មូលហេតុតែមួយគត់ដែលមេធាវីការពារក្តីបានផ្តល់ទាក់ទិននឹងសាក្សី អាចរកឃើញនៅក្នុងបណ្តឹងសារទុក្ខឧបសម្ព័ន្ធ II[20]។ នេះមិនពិតទេ។

២០. ជាបឋម នៅកិច្ចប្រជុំពេញអង្គនាខែសីហា ឆ្នាំ២០១២ មេធាវីការពារក្តីបានដាក់ចេញជាលម្អិតនូវមូលហេតុនានាសម្រាប់សំណើរបស់ខ្លួន សុំស្តាប់សក្ខីកម្មពីសាក្សីមួយចំនួន រួមទាំងបុគ្គលិកនៅស-២១ អតីតអ្នកជាប់ឃុំ និងអ្នកជំនាញផងដែរនៅក្នុងករណីបទចោទត្រូវបានពង្រីក[21]។ មូលហេតុនេះមានធាតុពិតនៅថ្ងៃនេះ[22]។

---

[19] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៦២។

[20] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៦២ អក្សរក្នុងលេខយោង ១១១ ។

[21] ឯកសារ E-1/114/.1 "ប្រតិចារិត-កិច្ចប្រជុំពេញអង្គ" ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ERN 00840164-00840303, pp 113:22-115:18 (បញ្ជាក់បន្ថែម): ខ្ញុំយល់ចំពោះ [កសព] វាជាប្រធានបទសំខាន់ ហើយចំពោះជំហររបស់យើងខ្ញុំ គឺថាប្រសិនបើ លោក/លោកស្រីចៅក្រមយល់ស្របជាមួយការវាយតម្លៃនោះ យើងត្រូវពិភាក្សាបញ្ហានេះ**ឲ្យបានពេញលេញ** ។ យើងមិនអាចមាន--និងខ្ញុំសូមទោសចំពោះការប្រើប្រាស់ពាក្យ ប៉ុន្តែខ្ញុំមានប្រើពាក្យនេះដោយចេតនា--យើងមិនអាចមាន "mini-trial" បានទេចំពោះ ស២១នោះ ដោយសារវាជាប្រធានបទសំខាន់--**ចំពោះសហព្រះរាជអាជ្ញា ។ ហើយប្រសិនបើយើងត្រូវដោះស្រាយបញ្ហាស២១ យើងត្រូវដោះស្រាយឲ្យបានល្អ មានន័យថាពុំមានផ្លូវកាត់ទេ**។ យើងត្រូវការពិភាក្សាលើអង្គហេតុ។ ចំពោះមេធាវីការពារក្តី គឺប្រាកដណាស់ថា ថាតើបញ្ហាស្នូលនៅស-២១ គឺជាអ្វី ។ **វាគឺជាភាពជឿទុកចិត្តបានរបស់ ឌុច** ។ ហើយយើងបានសួរចម្លើយ ឌុច ដែលជាផ្នែកនៃការជំនុំជម្រះដំណាក់កាលដំបូងនៅទីនេះ ប៉ុន្តែយើងមិនទទួលបានការជឿទុកចិត្តគាត់ពេញលេញនោះទេ ពិព្រោះវាស្ថិតនៅក្រៅវិសាលភាពនូវ**អ្វីដែលយើងត្រូវបានអនុញ្ញាតឲ្យសួរ ឌុច** ។ យើងនៅតែត្រូវការស្តាប់សក្ខីកម្មពីសាក្សីច្រើនទៀត ដែលអាចផ្តល់សក្ខីកម្មអំពីស-២១ ហើយពេលនោះវាអាចប្រាប់យើងច្រើនជាងនេះអំពីភាពជឿជាក់របស់ ឌុច ។ មានន័យថាយើងត្រូវស្នើបុគ្គលិកនៅស-២១ មកបង្ហាញខ្លួននៅទីនេះនៅបន្ទប់សវនាការ ដើម្បីផ្តល់សក្ខីកម្ម ពិព្រោះបុគ្គលិកទាំងនេះកាលពីការជំនុំជម្រះលើកទីមួយបានផ្តល់សក្ខីកម្មដែល**ផ្ទុយ**បញ្ហាមួយចំនួន ដែលឌុច បាននិយាយ ។ អ្នកនៅរស់រានមានជីវិតមួយចំនួនបានផ្តល់សក្ខីកម្ម ហើយសក្ខីកម្មខ្លះរបស់ពួកគេ**ផ្ទុយទៅនឹងបញ្ហាមួយចំនួន ដែល ឌុច បានផ្តល់សក្ខីកម្ម**។ ហើយយើងខ្ញុំក៏ស្នើសុំឲ្យស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញដូចអ្វីដែលបានធ្វើនៅក្នុងករណី០០១ ដែលអាចផ្តល់សក្ខីកម្មអំពីស-២១ និងអំពី ឌុច ដោយសារយើងត្រូវតែអាចជំទាស់ការ**ជឿជាក់លើសក្ខីកម្មរបស់ ឌុច**។ ហើយខ្ញុំបាននិយាយអំពីករណី០០១ ហើយខ្ញុំគិតថាវាសំខាន់ក្នុងការកត់សម្គាល់ថា យើងមិនអាចផ្អែកលើការវាយតម្លៃអង្គហេតុនៅក្នុងករណី០០១ បានទេ ។ ហើយខ្ញុំមិននៅទីនេះដើម្បីទាញអំណះអំណាង ឬលើកអំណះអំណាងឡើងវិញករណី០០១ នោះទេ ប៉ុន្តែការកត់សម្គាល់ពាក់ព័ន្ធមួយចំនួនគឺថា ដូចដែលលោកដឹង តាមពិតមេធាវីការពារក្តីនៅក្នុងករណី០០១ យល់ស្របលើចំណុចជាច្រើនជាមួយនឹងព្រះរាជអាជ្ញា។ ហេតុដូច្នេះការពិភាក្សាលើបញ្ហាជាក់លាក់មិនសូវខ្លាំងប៉ុន្មានទេ។ បញ្ហាមួយ

២១. បន្ថែមពីលើនេះ បន្ទាប់ពីត្រូវបានអនុញ្ញាតមេធាវីការពារក្តីបានគូសបញ្ជាក់ពីជំហររបស់ខ្លួនបន្ថែមទៀតទាក់ទិននឹងថា ហេតុអ្វីបានជាត្រូវស្តាប់សក្ខីកម្មពីសាក្សីដ៏ច្រើន ប្រសិនបើស-២១ នឹងត្រូវដាក់បញ្ចូលទៅក្នុងបទចោទនោះ។ មេធាវីការពារក្តីធ្វើយ៉ាងដូច្នេះមែននៅក្នុងសារអ៊ីម៉ែលក្រើនរំលឹកទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះ ហើយសំណៅនៃសារអ៊ីម៉ែលនេះបានបញ្ជូនទៅភាគីទាំងអស់(ឧបសម្ព័ន្ធI)[23]។ សារអ៊ីម៉ែលបញ្ជាក់ច្បាស់ថា [ស-២១] ជាប្រធានបទសំខាន់ និងស្មុគស្រាញដែលតម្រូវឱ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ ហើយការជំនុំជម្រះ នួន ជា ចំពោះបទចោទទាក់ទងស-២១ [...] ខណៈមិនអនុញ្ញាតមេធាវីការពារក្តីនូវឱកាសបង្ហាញសក្ខីកម្មសាក្សីដែលដេញដោលដោយផ្ទាល់នឹងភាពជឿជាក់របស់ ឌុច នឹងរំលោភសិទ្ធិរបស់ នួន ជា ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[24]។

---

ទៀតគឺថា ជនសង្ស័យនៅក្នុងករណី០០១ ឌុច សហការ ហើយគាត់ផ្តល់ចម្លើយ ។ ប៉ុន្តែជំហររបស់យើងគឺថា គាត់មានមូលហេតុដើម្បីបន្ធូរបន្ថយជំហររបស់គាត់ ហើយហេតុដូច្នេះ គាត់មិនបាននិយាយពិតនៅក្នុងសវនាការកាត់ទោសគាត់ទេ។ វាជាការសំខាន់ដើម្បីធ្វើការកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានទទួលស្គាល់ចំណុចនេះនៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយនៅក្នុងករណី០០១។ ពួកគេលើកឡើងនៅក្នុងឯកសារថា សក្ខីកម្មរបស់ ឌុច នៅពេលនោះមិនស្មោះត្រង់។ ជារួម**យើងមិនអាចផ្អែកលើករណី០០១ទេ**។នៅករណី០០១សវនាការលើភស្តុតាងប្រើពេល៧២ថ្ងៃ ។ មានសាក្សីអង្គហេតុ១៧នាក់ សាក្សីពីចរិតលក្ខណៈ៧នាក់ ដើមបណ្តឹងរដ្ឋប្បវេណី២២នាក់ និងសាក្សីអ្នកជំនាញ៩នាក់។ ខ្ញុំមិនលើកឡើងថា យើងត្រូវការចំនួនថ្ងៃស្រដៀងគ្នាទេ ដើម្បីនិយាយអំពីស-២១ ប្រសិនបើធ្វើជាផ្នែកនៃករណីមែន ប៉ុន្តែ**យើងត្រូវការចំនួនសាក្សីច្រើនល្មម ដើម្បីឱ្យយើងអាចវាយតម្លៃភាពជឿជាក់បានរបស់ ឌុច**។

[22] យ៉ាងហោចណាស់អង្គជំនុំជម្រះសាលាដំបូងត្រូវតែបានជឿដោយអំណះអំណាងមួយចំនួន ដែលនាំឱ្យអង្គជំនុំជម្រះសម្រេចថា សាក្សីជាច្រើនទាក់ទិននឹងស-២១ ត្រូវតែមកផ្តល់សក្ខីកម្ម ជាផ្នែកនៃការជំនុំជម្រះដោយយុត្តិធម៌ ដែលនឹងបង្កឱ្យមានអូសបន្លាយពេលវេលានៅក្នុងសំណុំរឿង០០២/០១។

[23] ពិតណាស់ការប្រាស្រ័យទាក់ទងទាំងនេះតាមសារអ៊ីម៉ែលគ្រោះថ្នាក់ដល់តម្លាភាពនៃកិច្ចដំណើរការនិតីវិធី តែក៏ដោយសារមូលហេតុនោះដែលមេធាវីការពារក្តី នួន ជា នៅក្នុងអំឡុងពេលសវនាការផ្ទាល់មាត់ស្នើដែលៗអង្គជំនុំជម្រះសាលាដំបូងឱ្យពិចារណាបញ្ហានានាដែលទាក់ទងនឹងការជ្រើសរើសសាក្សីជាសាធារណៈ ។ សាធារណជនមានសិទ្ធិដឹងថា តើសាក្សីណាដែលភាគីស្នើ ហើយហេតុអ្វីបានជ្រើសរើសសាក្សី។ សូមមើលឯកសារ E-212 "សំណើសុំការពិភាក្សាដេញដោលផ្ទាល់មាត់ជាសាធារណៈទាក់ទងនឹងការកោះហៅសាក្សីរបស់មេធាវីការពារក្តី" ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ ERN 00818577-00818588 (ដែលអង្គជំនុំជម្រះសាលាដំបូងមិនទាន់សម្រេចនៅឡើយទេ)។

[24] សូមមើលឧបសម្ព័ន្ធភ្ជាប់សារណាឆ្លើយតបនេះ។

២២. វាសមហេតុផលក្នុងការលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងយល់ស្របជាមួយអំណះអំណាងមួយចំនួនរបស់មេធាវីការពារក្តី និងសម្រេចថាការវាយតម្លៃត្រឹមត្រូវមួយពីឧក្រិដ្ឋកម្មនៅស-២១ និងឧក្រិដ្ឋកម្មពាក់ព័ន្ធដទៃទៀត នឹងបង្កហានិភ័យដល់ការអូសបន្លាយពេលវេលានៃការជំនុំជម្រះ។ ស្រដៀងគ្នានេះដែរ លទ្ធភាពដែលថាអង្គជំនុំជម្រះត្រូវបានធ្វើឲ្យជឿដោយអំណះអំណាងរបស់សហព្រះរាជអាជ្ញាដែលថា ការវាយតម្លៃត្រឹមត្រូវមួយពីអង្គហេតុនៅស្រុក១២ នឹងត្រូវការសាក្សីយ៉ាងតិច១២នាក់ដែលត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា ដែលចំនួននេះមិនច្រើនពេកទេ។ អាស្រ័យហេតុនេះ វាមិនមែនមិនសមហេតុផលក្នុងការលើកឡើងថា ការកោះហៅសាក្សីអាចនាំឲ្យពន្យារកិច្ចដំណើរការនិតីវិធីមិនសមហេតុផលនោះទេ។ ដើម្បីឈានទៅរកការធ្វើសេចក្តីសន្និដ្ឋានទាំងនេះ អង្គជំនុំជម្រះសាលាដំបូង មិនត្រូវការវាយតម្លៃឲ្យបានលំអិតនូវតំលៃរបស់សាក្សីនិមួយៗ និងសាក្សីទាំងអស់ដែលស្នើឡើងដោយភាគីនោះទេ និងសម្រេចថា តើត្រូវកោះហៅ ឬមិនកោះហៅសាក្សីនិមួយៗក្នុងចំណោមពួកគេដែរ[25]។ និយាយម្យ៉ាងទៀត វាសមហេតុផលទាំងស្រុងសម្រាប់អង្គជំនុំជម្រះសាលាដំបូងរក្សាការយល់ដឹងបឋម (prima facie understanding) នៃចំនួនសាក្សីចំនួនប៉ុន្មាននាក់ដែលនឹងត្រូវស្នើឡើងដោយភាគី និងថាតើអំណះអំណាងរបស់ពួកគេមានទម្ងន់ខ្លាំងកម្រិតណាដើម្បីកោះហៅសាក្សីទាំងនេះ និងដើម្បីផ្អែកសេចក្តីសម្រេចរបស់ខ្លួនថា តើត្រូវពង្រីក ឬមិនត្រូវពង្រីកការចោទប្រកាន់ដោយផ្អែក

---

[25] ដើម្បីឲ្យប្រាកដ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវការស្វែងព័ត៌មានលំអិតទាក់ទងនឹងសាក្សី ដែលនឹងត្រូវស្នើឡើង ។ ចំណុចនេះក៍ត្រូវដែរ ដោយសារការជ្រើសរើសសាក្សីនឹងពាក់ព័ន្ធ ប្រសិនបើ (និងប្រសិនបើតែ) ការពង្រីកត្រូវបានអនុញ្ញាតតែប៉ុណ្ណោះ ហើយមានតែនៅពេលនោះទេដែលសេចក្តីសន្និដ្ឋានស្ពាព និងលំអិត នឹងតម្រូវ ហើយរហូតទល់ពេលនោះមូលហេតុសង្ខេបនឹងលេចរូបរាង។ ចំណុចនេះក៍បានរំលេចឡើងដោយចំណាងជើងនៃចំណុច៧ នៃការប្រាស្រ័យទាក់ទងគ្នាអំពីកិច្ចប្រជុំពេញអង្គ ដែលបង្ហាញនៅក្នុងសារអ៊ីម៉ែលនៅក្នុងឧបសម្ព័ន្ធ I: *សាក្សីបន្ថែមដែលភាគីបានស្នើ នឹងត្រូវបានកោះហៅ បើសិនសំណើពង្រីកការចោទប្រកាន់ត្រូវបានអនុញ្ញាត*។ លើសពីនេះទៀត អង្គជំនុំជម្រះដឹងច្បាស់ពីកម្មវត្ថុ និងសាក្សីដែលបានស្នើឡើងទាក់ទងនឹងស២១ ដោយសារតែអង្គជំនុំជម្រះសាលាដំបូងបានជំនុំជម្រះ ឌុច ដូច្នេះវាត្រូវតែមានការសន្មតជាមុនថា អង្គជំនុំជម្រះអាចវាយតម្លៃបានត្រឹមត្រូវអំពីតម្រូវការពេលវេលាសម្រាប់ការពិភាក្សាអង្គហេតុនៅស២១។

លើការវាយតម្លៃនេះ[26]។ ប្រការនេះមានក្នុងវិសាលភាពនៃយុត្តាធិការដែលវិធាន៨៩ ស្ទួនពីរបាន ប្រគល់ឲ្យអង្គជំនុំជម្រះសាលាដំបូង។

*ការព្រួយបារម្ភតាមការរំពឹងទុកអំពីការអនុវត្តត្រូវបានវាយតម្លៃសមហេតុផល*

២៣. ជាទូទៅគេត្រូវតែបានកត់សម្គាល់ថា សហព្រះរាជអាជ្ញាជំទាស់ដល់ការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងអំពីភាពស្មុគស្មាញតាមការរំពឹងទុក នៅក្នុងការកម្រិតវិសាលភាពនៃការពង្រីកដែលបានស្នើឡើង[27] ដោយបានសំអាងលើការជំទាស់តាមការរំពឹងទុករបស់មេធាវីការពារក្តី[28] និងការខកខានមិន បានវាយតម្លៃត្រឹមត្រូវលើចំនួនសាក្សីបន្ថែមដែលត្រូវផ្តល់សក្ខីកម្ម[29]។ ជាពិសេស សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះមានឧបករណ៍ និងអំណាចដែលពាក់ព័ន្ធ ដើម្បីទប់ទល់នឹងភាពស្មុគស្មាញតាមរំពឹងទុកទាំងអស់នោះ ដោយគ្រាន់តែអនុវត្តបច្ចេកទេសការគ្រប់គ្រងសវនាការដែលអង្គជំនុំជម្រះបានប្រើមកដល់ពេលនេះ[30]។ ប៉ុន្តែគេអាចទាញការសន្និដ្ឋានពីសេចក្តីសម្រេចថា អង្គជំនុំជម្រះប្រមើលថា *បើទោះបីជាប្រើបច្ចេកទេសនិងអំណាចដែលខ្លួនបានប្រើសម្រាប់ការគ្រប់គ្រងការជំនុំជម្រះមកទល់ពេលនេះ* ក៏ហានិភ័យដល់ការពន្យាពេលវេលាច្រើនគួរសម្បដែរ[31]។ នេះគឺជាការសន្មតសម

[26] តាមពិតការដែលថាអង្គជំនុំជម្រះសម្រេចកម្រិតការពិភាក្សាលើអង្គហេតុនានាទាក់ទងនឹងទួលពជ័យ និងឧប្បត្តិហេតុនានាដែលកើតឡើងភ្លាមៗ បន្ទាប់ពីការជន្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ បង្ហាញថាអង្គជំនុំជម្រះពិតជាបានពិចារណាសំណើររបស់សហព្រះរាជអាជ្ញា ហើយស្របពេលជាមួយគ្នានេះក៏បានយកចិត្តទុកដាក់អំពីការតម្រូវឲ្យពន្លឿនការជំនុំជម្រះដែរ ។

[27] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៥៤ ដល់៥៧ ។

[28] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៥១ ដល់៥៣ ។

[29] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៥៨ ដល់៦៨ ។

[30] បណ្តឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៥២-៥៥, ៥៧ និងកថាខណ្ឌ ៦៦ ដល់៦៧ ។

[31] ការព្រួយបារម្ភរបស់អង្គជំនុំជម្រះពិតជាសមហេតុផល ។ មេធាវីការពារក្តីបានចង្អុលបង្ហាញរួចហើយថា ខ្លួនត្រូវការរយៈពេលបួនខែដើម្បីរៀបចំឲ្យមានប្រសិទ្ធិភាពសម្រាប់ ស- ២១ តែឯង។ (សូមមើលឯកសារ E- 1/ 114.1 “ប្រតិចារិត” នៃកិច្ចប្រជុំរៀបចំសវនាការ” ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ ERN 00840164-00840303, pp 115:19-24) . ច្បាស់ណាស់ថាចំនួនសាក្សីដ៏ច្រើនដែលត្រូវកោះហៅឲ្យផ្តល់សក្ខីកម្មដើម្បីវាយតម្លៃអង្គហេតុ នឹងត្រូវប្រើប្រាស់ពេលវេលាច្រើន ។ (សម្រាប់មូលហេតុដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ និងនៅក្នុងសារអេឡិចត្រូនិកទៅកាន់មន្ត្រីជាន់ខ្ពស់ (ឧបសម្ព័ន្ធ១) អង្គជំនុំជម្រះមិនអាចផ្អែកការលើការរកឃើញនៅក្នុងករណី០០១ ឡើយ ។ ដើម្បីឲ្យប្រាកដ ដោយពិចារណាថាភាពជឿជាក់របស់ ឌុច គឺជាបញ្ហាស្នូលដល់មេធាវី

ហេតុផលអំពីអំណាចតាមឆន្ទានុសិទ្ធិក្នុងការគ្រប់គ្រងសវនាការរបស់អង្គជំនុំជម្រះ(ដែលអង្គជំនុំជម្រះមិនបានស្ទាក់ស្ទើរដើម្បីប្រើប្រាស់វាពីអតីតកាលឡើយ ឧទាហរណ៍អំណាចនេះត្រូវបានប្រើប្រាស់ដើម្បីកំណត់កាលបរិច្ឆេទកោះហៅសាក្សីដោយជូនដំណឹងយ៉ាងប្រថុចប្រញ៉ុក និងលុបចោលការផ្ដល់សក្ខីកម្មនៃសាក្សី) ដោយផ្អែកលើអង្គហេតុនៅចំពោះមុខអង្គជំនុំជម្រះ។

២៤. ការកត់សម្គាល់នេះត្រូវបានពង្រឹងដោយការដែលថា អង្គជំនុំជម្រះបានពិចារណាយ៉ាងម៉ត់ចត់ និងប្រកបដោយវិរយភាពទៅលើសំណើរបស់សហព្រះរាជអាជ្ញា តាមរយៈរបៀបនៃការដាក់បន្ថែមការសម្លាប់នៅទួលពោធិ៍ជ្រៃ ដោយហេតុថាវាជាហេតុការណ៍ដែលបានកើតឡើងភ្លាមៗបន្ទាប់ពីមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ប៉ុន្តែមិនមែនហេតុការណ៍ដែលបានកើតឡើងនៅចន្លោះ ឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧នោះទេ[32]។ និយាយម្យ៉ាងទៀត អង្គជំនុំជម្រះបានពិចារណាសំណើរបស់សហព្រះរាជអាជ្ញាយ៉ាងម៉ត់ចត់ និងបានចេញសេចក្ដីសម្រេចដែលន័យយ៉ាងច្បាស់ និងអាចវាស់បាន ដោយស្របពេលជាមួយគ្នានេះរក្សាបានសេចក្ដីត្រូវការរក្សាចំណងទាក់ទងជាមួយការចោទប្រកាន់ចំពោះអង្គហេតុដែលមាន។

### ឃ. អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃត្រឹមត្រូវលើទំនាក់ទំនងរវាងវិសាលភាពនៃការជំនុំជម្រះបច្ចុប្បន្ន និងការពង្រីកវិសាលភាពនេះដែលបានស្នើឡើង

---

ការពារក្ដី អ្នកចិត្តសាស្ត្រដែលរៀបចំរបាយការណ៍អំពីបុគ្គលិកលក្ខណៈរបស់គាត់ គឺជាសាក្សីដ៏សំខាន់។ ឯកសារទាក់ទងនឹងស២១ត្រូវតែយកមកពិភាក្សាឲ្យបានពេញលេញ ច្រើនជាងឯកសារដទៃទៀតនៅក្នុងសំណុំរឿង ពិព្រោះកិច្ចការទាំងឡាយនៅស២១ហាក់ដូចជាត្រូវបានចងក្រងយ៉ាងល្អ និងផ្ទុយនឹងការថ្លែង និងការចងចាំរបស់ ឌុច ។ មួយវិញទៀតបញ្ហាឯកសារដែលបានប្រមូលដោយវៀតណាម នៅតែជាបញ្ហាដែលត្រូវដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង។ គេត្រូវតែចាំថាវិសាលភាពនៃការស្ដាប់សក្ខីកម្ម ឌុច ត្រូវបានធ្វើឡើងដោយដាក់កម្រិតយ៉ាងខ្លាំង ហើយហេតុដូច្នេះ ឌុច ត្រូវតបានស្ដាប់សក្ខីកម្មឡើងវិញ ហើយដូចដែលបានលើកអំណះអំណាងរួចហើយ សាក្សីដោះបន្ទុកត្រូវតែបានអនុញ្ញាតឲ្យផ្ដល់សក្ខីកម្មដើម្បីដេញដោលលើភាពជឿជាក់របស់គាត់ ។ និយាយក្នុងន័យទូទៅ ជាមួយការពង្រីកបទចោទទាក់ទងនឹងស២១ សាក្សីដ៏ដៃទៀតដែលបានផ្ដល់សក្ខីកម្មរួចហើយលើអង្គហេតុដទៃទៀតឥឡូវនេះត្រូវបានសាកសួរលើបញ្ហាទូលំទូលាយ រួមទាំងការសម្លាប់ទាហានលន់ ណុល ទីកន្លែងសម្លាប់មនុស្ស និងមន្ទីរសន្តិសុខ។

[32] ការជូនដំណឹងអំពីសេចក្ដីសម្រេច លើសំណើរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ៣។

២៥. នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន អង្គជំនុំជម្រះបានកត់សម្គាល់ថា "ខ្លួននៅតែមិនមានជំនឿថាទីតាំងឧក្រិដ្ឋកម្មបន្ថែមទាំងនេះ មិនជាប់ពាក់ព័ន្ធជិតស្និទជាមួយការចោទប្រកាន់ចំពោះអង្គហេតុនៅក្នុងសំណុំរឿង០០២/០១ឡើយ[33]។ នេះគឺជាការវាយតម្លៃលើអង្គហេតុដែលស្ថិតនៅក្នុងរង្វង់ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។

២៦. ប៉ុន្តែបណ្ដឹងសារទុក្ខភ្លាមៗអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខាន "មិនបានវាយតម្លៃត្រឹមត្រូវទំនាក់ទំនង និងលំដាប់លំដោយសមហេតុផលរវាងវិសាលភាពនៃការជំនុំជម្រះបច្ចុប្បន្ន និងស២១ និងការសម្លាប់មនុស្សនៅស្រុក១២" ។ សហព្រះរាជអាជ្ញាអះអាងថាមានទំនាក់ទំនាងរវាងការជម្លៀសប្រជាជនដោយបង្ខំពីទីក្រុងភ្នំពេញ និងការសម្លាប់នៅស្រុក១២ និងនៅទួលពោធិជ្រៃ និងស២១[34]។ ពុំមានទំនាក់ទំនងបែបនេះទេ ហើយតាមពិតសហព្រះរាជអាជ្ញាមិនអាចបង្ហាញទៀតផង[35]។

២៧. ពិតណាស់ការចោទប្រកាន់ចំពោះអង្គហេតុនៅក្នុងសំណុំរឿង០០២/០១ ទាក់ទិនទៅនឹងការបំផ្លាស់ទីលំនៅរបស់ប្រជាជននៅដំណាក់ទី១ និងដំណាក់កាលទី២[36]។ ដោយសារសហព្រះរាជអាជ្ញាមិនបានប៉ុនប៉ងភ្ជាប់ ស-២១ ទៅនឹងការបផ្លាស់ទីលំនៅរបស់ប្រជាជននៅដំណាក់ទី២ ការពិភាក្សាដេញដោលត្រូវតែកម្រិតការបំផ្លាស់ទីលំនៅរបស់ប្រជាជននៅដំណាក់ទី១ ដែលនេះគឺជាការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ។ ពុំមានអង្គហេតុសមហេតុផល ឬដែលអាចឲ្យជឿបាន តភ្ជាប់គ្នារវាងការជម្លៀសប្រជា

---

33 ការជូនដំណឹងអំពីសេចក្ដីសម្រេច លើសំណើរបស់សហព្រះរាជអាជ្ញា នៅកថាខណ្ឌ២។

34 បណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៧៥ ។

35 សហព្រះរាជអាជ្ញាព្យាយាមភ្ជាប់ទីតាំងថ្មីទៅនឹងអង្គហេតុដែលមាន តាមរយៈការពិនិត្យមើលគោលនយោបាយមិនច្បាស់លាស់របស់បក្សកុម្មុញនីស្តកម្ពុជា ដើម្បីកម្ទេចសត្រូវរបស់ខ្លួន (បណ្ដឹងសារទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញានៅកថាខណ្ឌ៧១)។ បញ្ហានេះនឹងពិភាក្សនៅកថាខណ្ឌ៣១-៣២ ខាងក្រោម។

36 ឯកសារ E-124/7.3, "ឧបសម្ព័ន្ធ-បញ្ជីនៃកថាខណ្ឌ និង ផ្នែកនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១ ដែលត្រូវបានកែប្រែបន្ថែមចំពោះសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសម្បទារបស់ អៀង ធិរីទ្ធ ដើម្បីចូលរួមសវនាការ (E138) និងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើសំណើរបស់សហព្រះរាជអាជ្ញា សុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មទៅក្នុងវិសាលភាពនៅក្នុងសំណុំរឿង០០២/០១ (E-163) ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ERN 00852356-00852358 [ឧបសម្ព័ន្ធ-បញ្ជីនៃកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១] ។ ចំពោះការដាក់បញ្ចូលថ្មីៗនេះនៃការសម្លាប់មនុស្សនៅទួលពោធិជ្រៃ និងការសម្លាប់ទាហានលន់ ណុន ចំពោះការពិចារណាអង្គហេតុនៃករណីនេះ សូមមើលកថាខណ្ឌ៣៣-៣៤ ខាងក្រោម។

ជនពីទីក្រុងភ្នំពេញ និងមន្ទីរស-២១ ។ អនុលោមតាមដីកាដំណោះស្រាយ ប្រជាជនដែលជម្លៀសពីទីក្រុងភ្នំពេញ ត្រូវបានគេបញ្ជូនទៅជនបទ *មិនមែន*ទៅមន្ទីរស-២១ នោះទេ។ វាអាចទៅរួចបើសិនជាពិចារណាថា ការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញត្រូវបានបញ្ចប់ពីរទៅបីសប្តាហ៍ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥[37] តែមន្ទីរស-២១ ប្រតិបត្តិការពេញលេញនៅខែតុលា ឆ្នាំ១៩៧៥ ទៅវិញទេ[38]។

២៨. ម្យ៉ាងទៀត ពុំមានការចង្អុលបង្ហាញថាមានប្រជាជនត្រូវបានបញ្ជូលទៅមន្ទីរស-២១ទេ ព្រោះពួកគេជាអ្នកជម្លៀសពីក្រុងភ្នំពេញ[39]។ អនុលោមតាមដីកាដំណោះស្រាយសកម្មភាពរបស់ ស-២១ គឺខុសគ្នាទាំងស្រុង។ តួនាទីសំខាន់របស់ ស-២១ គឺយកចម្លើយសារភាពពីអ្នកទោស ដើម្បីរែកមុខបណ្ដាញក្បត់ផ្សេងទៀត[40]។ អនុលោមតាម កសចស "ក្រុមអ្នកទោសសំខាន់របស់ ស-២១ គឺអតីតសមាជិកនៃកងទ័ពបដិវត្តន៍កម្ពុជា (៥.៦០៩ នាក់ យោងលើបញ្ជីឈ្មោះដែលបានកែប្រែរួច) ។ អ្នកទោសក្រុមទីពីរដែលមានចំនួនច្រើន គឺជាកម្មាភិបាលនៃបក្សកុម្មុយនីស្តកម្ពុជា (៤.៣៧១នាក់ យោងលើបញ្ជីឈ្មោះដែលបានកែប្រែរួច)[41]។ និយាយម្យ៉ាងទៀត អនុលោមតាមការរៀបរាប់នេះ ស-២១ គឺមានតួនាទីរែកមុខ ត្រួសត្រាយ និងវាយបំបាក់ក្រុមប្រឆាំងផ្ទៃក្នុងនៃកងទ័ពបដិវត្តន៍កម្ពុជា និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា។ ចំណុចនេះញែក ស-២១ ពីអង្គហេតុដែលបានចោទប្រកាន់នៅជុំវិញការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ហើយការជម្លៀសនេះទៀតសោតមិនបានធ្វើឡើងចំពោះអ្នកប្រឆាំងផ្ទៃក្នុងទេ តែប៉ះពាល់អ្នកខាងក្រៅបក្សទៅវិញទេ គឺប្រជាជនទីក្រុងភ្នំពេញ ។

២៩. បើគិតតាមពេលវេលា ដើម្បីដឹងថាអង្គហេតុទាក់ទងនឹងមន្ទីរស២១ មិនពាក់ព័ន្ធទៅនឹងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ គេគ្រាន់តែពិចារណាអំពីថេរវេលាដែលមន្ទីរស២១ បានកើតឡើងប៉ុណ្ណោះ

---

[37] ឯកសារ D-427 "ដីកាដំណោះស្រាយ" ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ERN 00604508-00605246 នៅកថាខណ្ឌ 224 ("ដីកាដំណោះស្រាយ)។

[38] ដីកាដំណោះស្រាយ នៅកថាខណ្ឌ៤១៦ ។

[39] អាចមានប្រជាជនមួយចំនួនដែលជម្លៀសចេញពីទីក្រុងភ្នំពេញ ត្រូវបានគេយកទៅឃុំនៅស២១ តែចំនួននេះមិនច្រើនទេ ហើយអ្វីដែលសំខាន់ ការដែលថាពួកគេត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ មិនមែនជាលក្ខខណៈវិនិច្ឆ័យដែលត្រូវបានប្រើសម្រាប់ការឃុំខ្លួនទេ។

[40] ដីកាដំណោះស្រាយ នៅកថាខណ្ឌ៤៥៥ ។

[41] ដីកាដំណោះស្រាយ នៅកថាខណ្ឌ៤២៤-៤២៥ ។

(រហូតដល់ខែមករា ឆ្នាំ១៩៧៩) ដូច្នេះគេមិនចាំបាច់យកបញ្ហានេះមកពិភាក្សាជាផ្នែកនៃសំណុំរឿង ០០២/០១ ឡើយ។ ការពិភាក្សាអំពីអង្គហេតុដែលពាក់ព័ន្ធនឹងមន្ទីរ ស២១ នឹងបង្កើនវិសាលភាពពេលវេលាយ៉ាងធំធេងនៃសំណុំរឿង០០២/០១ ហើយដូច្នេះអាចពន្យាដល់កិច្ចដំណើរការនីតិវិធី[42]។ ពិតណាស់មេធាវីការពារ នួន ជា នឹងស្នើសុំដោយសមហេតុផលឲ្យមានការវាយតម្លៃស៊ីជម្រៅទៅលើអង្គហេតុនានាទាក់ទងនឹងប្រតិបត្តិការនៅមន្ទីរ ស២១ ក្នុងអំឡុងពេលដែល នួន ជា ត្រូវបានគេចោទប្រកាន់ថាទទួលខុសត្រូវដោយផ្ទាល់ក្នុងការគ្រប់គ្រងទីក្រុងភ្នំពេញ ពោលគឺចាប់ពីខែ សីហា ឆ្នាំ ១៩៧៧[43] ដល់ដើមឆ្នាំ១៩៧៩ ដែលពេលវេលានេះវាឃ្លាតចាកឆ្ងាយពីពេលវេលាដែលកំពុងស្ថិតក្រោមការពិភាក្សាក្នុងសំណុំរឿង ០០២/០១។

៣០. ការប៉ុនប៉ងតែមួយគត់ដែលសហព្រះរាជអាជ្ញាបានធ្វើឡើងដើម្បីភ្ជាប់មន្ទីរ ស២១ ទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺតាមរយៈការលើកឡើងការអះអាងដដែលៗមិនគួរឲ្យជឿជាក់ដែលខ្លួនបានធ្វើជាលើកទី១: នៅក្នុងការស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងបញ្ចូលមន្ទីរស២១ ទៅក្នុងសំណុំរឿង០០២/០១ សហព្រះរាជអាជ្ញាបានលើកឡើងថា៖ "ការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺផ្អែកលើមូលដ្ឋានដែលថាបក្សនឹងអាចវែកមុខ"សត្រូវ" និងកម្ទេចពួកគេចោលនៅមន្ទីរសន្តិសុខ និងវាលពិឃាតនានា[44] នៅពេលដែលប្រជាជនចាកចេញពីទីក្រុង" ។ ដូច្នេះ ដោយទុកការគាំទ្រដែលមិនសូវរឹងមាំចំពោះគោលជំហរខាងលើនេះមួយផ្នែកសិន[45] គេមិនអាចប្រកែកបានទេថា

---

[42] ឧទាហរណ៍ គេអាចស្មានទុកជាមុនទាំងស្រុងបានថាការពិភាក្សាអំពីចម្លើយសារភាពដែលបានមកពី ស២១ របស់មន្ត្រីជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាមួយចំនួន ដូចជា ហ៊ូ នឹម, វន វ៉េត, ម៉ែន សាន, វស់ ញឹម, គង់ សុផល ឬ ឃ្លាំង ចាប (សូមមើលដីកាដំណោះស្រាយកថាខណ្ឌ៤២៥) គឺតម្រូវឲ្យមានការពិភាក្សាក្នុងនៅក្នុងសាលសវនាការលើកាលៈទេសៈជាក់លាក់មួយចំនួនទាក់ទងនឹងអង្គហេតុ និងនយោបាយដែលពាក់ព័ន្ធនឹងចម្លើយសារភាបជាក់លាក់នោះ និងលើអំឡុងពេលនៃការទទួលបានចម្លើយសារភាពទាំងនោះ។ ធ្វើដូច្នេះអាចធ្វើឲ្យកម្រិតនៃអង្គហេតុដែលស្ទើរតែគ្មានដែនកំណត់ទៅហើយពីឆ្នាំ១៩៧៥ដល់ ១៩៧៩ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង០០២/)០១។

[43] សូមមើលដីកាដំណោះស្រាយ, កថាខណ្ឌ៤២១។

[44] បណ្តឹងសាទុក្ខភ្ជាមៗរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧៤។

[45] ដូចដែលបានឃើញក្នុងឯកសារ E-163, សំណើរបស់សហព្រះរាជអាជ្ញាសុំដាក់បញ្ចូលកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១, ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២, ឯកសារ ERN 00759910-00759921,

វាគ្មានការពាក់ព័ន្ធរវាង"សត្រូវ"ដែលជាគោលដៅក្នុងអំឡុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និង "សត្រូវ" ដែលជាគោលដៅនៅមន្ទីរ ស២១ ឡើយ។

*ការពឹងផ្អែករបស់សហព្រះរាជអាជ្ញាទៅលើ "គោលនយោបាយ" គឺជាការយល់ខុស*

៣១. សហព្រះរាជអាជ្ញាបានគូសបញ្ជាក់ថា ព្រឹត្តការណ៍ឧក្រិដ្ឋកម្មដំបូងពីរ (ការម្លៀសប្រជាជនចេញពី ទីក្រុងភ្នំពេញ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ) គឺពាក់ព័ន្ធដោយផ្ទាល់ និងស្មុគស្មាញទៅនឹងគោលនយោបាយឧក្រិដ្ឋរបស់របបកម្ពុជាប្រជាធិបតេយ្យដើម្បីកម្ទេចជនដែលពួកគេចាត់ទុកថាជាសត្រូវ-គោលនយោបាយដែលអនុវត្តនៅមន្ទីរ ស២១ និងនៅទូទាំងវាលពិឃាតស្រុក១២[46]។ ភាសានេះបញ្ជាក់ច្បាស់ថាសហព្រះរាជអាជ្ញាពិតជាខកខានមិនបានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវផ្សេងគ្នាដែលអង្គជំនុំជម្រះសាលាដំបូងបានប្រើដើម្បីឈានដល់ការធ្វើសេចក្ដីសម្រេចរបស់ខ្លួនឡើយ : អង្គជំនុំជម្រះសាលាដំបូងបានវាយតម្លៃយ៉ាងសមហេតុផលថាតើ "កន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមទាំងនេះបានពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងការចោទប្រកាន់ផ្អែក*អង្គហេតុ*ដែលមានស្រាប់ក្នុងសំណុំរឿង ០០២/០១ ដែរឬទេ[47]"។ ពិតណាស់ ការចោទប្រកាន់ផ្អែក *អង្គហេតុ* គឺគ្រាន់តែជាការសម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញជាក់ស្ដែងនិងការផ្លាស់ទីលំនៅប្រជាជនជាក់ស្ដែងក្នុងដំណាក់កាលទី២ប៉ុណ្ណោះ[48] ហើយគ្មានការ

---

កថាខណ្ឌទី១០ : ការគាំទ្រតែមួយគត់ចំពោះការអះអាងនេះគឺជាការដកស្រង់ដ៏ខ្លីតែមួយគត់ដោយ ខុច។ ក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា (កថាខណ្ឌ៧២) ការអះអាងរបស់ខ្លួនដែលថាគោលនយោបាយរបស់បក្សកុម្មុនីស្តកម្ពុជាក្នុងការវែកមុខ ជីកឬសគល់ និងកម្ទេចសត្រូវរបស់ខ្លួន គឺជាកត្តាចម្បងក្នុងការគាំទ្រសេចក្ដីសម្រេចជម្លៀសប្រជាជនក្នុងខែមេសា ឆ្នាំ១៩៧៥ គឺត្រូវបានគាំទ្រដោយការរកឃើញដែលមានក្នុងដីកាដំណោះស្រាយត្រង់កថាខណ្ឌ២៤៨។ ការពិនិត្យមើលកថាខណ្ឌ នេះដោយយកចិត្តទុកដាក់បង្ហាញថាវាជាការនិយាយបំផ្លើសសុទ្ធសាតដល់ការរកឃើញរបស់សហចៅក្រមស៊ើបអង្កេត។ ជាងនេះទៅទៀត ក្នុងដីកាដំណោះស្រាយ អំណះអំណាងជាច្រើនត្រូវបានលើកមកពិភាក្សា (កថាខណ្ឌ២៤២ ដល់២៤៩) ដោយមិនគិតថាតើចុងក្រោយអង្គជំនុំជម្រះសាលាដំបូងនឹងសម្រេចលើបញ្ហានេះយ៉ាងម៉េចឡើយ។ ការអះអាងដោយទទេស្អាតរបស់ សហព្រះរាជអាជ្ញាដែលថាគោលនយោបាយវែកមុខ ជីកឬសគល់ និងកម្ទេចសត្រូវរបស់បក្ស គឺជាកត្តាចម្បងដែលគាំទ្រការសម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ គឺគ្មានអ្វីក្រៅតែពីការសន្និដ្ឋានទទេស្អាតឡើយ។

[46] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៧១។

[47] សេចក្ដីជូនដំណឹងអំពីសេចក្ដីសម្រេចលើសំណើសហព្រះរាជអាជ្ញា, កថាខណ្ឌទី២ (គូសបញ្ជាក់បន្ថែម)។

[48] ទាក់ទងទៅនឹងការបន្ថែមវាលពិឃាតទួលពោធិ៍ជ្រៃ, សូមមើលកថាខណ្ឌ៣៣ដល់៣៤ខាងក្រោម។

ពាក់ព័ន្ធ “ដោយផ្ទាល់ និងស្មុគស្មាញ” រវាងអង្គហេតុទាំងនោះ ទៅនឹងបទចោទថ្មីៗដែលសហព្រះរាជអាជ្ញាបានលើកឡើងឡើយ។

៣២. ផ្ទុយទៅវិញសហព្រះរាជអាជ្ញា ព្យាយាមបញ្ចុះបញ្ចូលអង្គជំនុំជម្រះតុលាការកំពូលថាព្រឹត្តិការណ៍ទាំងនេះគឺជាផ្នែកមួយនៃ*គោលនយោបាយ*ជាក់លាក់ (ដែលត្រូវបានកំណត់និយមន័យយ៉ាងទូលំទូលាយថាជាគោលនយោបាយ“កម្ទេចសត្រូវ”) ហើយគោលនយោបាយនេះក៏ត្រូវបានអនុវត្តនៅមន្ទីរ ស២១ និងនៅទីសម្លាប់មនុស្សនៅស្រុក១២ដែរ។ ប៉ុន្តែប្រសិនបើបុគ្គលម្នាក់ទទួលយកសំអាងហេតុនេះ បុគ្គលនោះនឹងចាកឆ្ងាយទាំងស្រុងពីមូលដ្ឋាន*អង្គហេតុ*នៃសំណុំរឿង០០២/០១ (ការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងដំណាក់កាលទី២)។ លក្ខខណៈវិនិច្ឆ័យប្រកបដោយអត្ថន័យសម្រាប់កំណត់ចំនួនអង្គហេតុដែលត្រូវពិភាក្សាក្នុងសំណុំរឿង០០២/០១ នឹងត្រូវបាត់បង់ ព្រោះអង្គហេតុទាំងអស់ក្នុងដីកាដំណោះស្រាយទាំងមូល នឹងត្រូវភ្ជាប់ទៅនឹងគោលនយោបាយនៃការកម្ទេចសត្រូវដែលគេបានសន្មតទុកជាមុនយ៉ាងទូលំទូលាយនេះ។ ម្យ៉ាងវិញទៀត បញ្ហាថាតើអង្គហេតុជាក់លាក់មួយចំនួនបង្កើតបានជាផ្នែកមួយនៃគោលនយោបាយកម្ទេចសត្រូវរបស់បក្សកុម្មុយនីស្តដែរ ឬយ៉ាងណានោះ គឺមិនមែនជាលក្ខណៈវិនិច្ឆ័យដែលអាចយកមកអនុវត្តបានឡើយ នៅពេលដែលធ្វើការវាយតម្លៃថាតើអង្គហេតុណាមួយគួរតែបង្កើតបានជាផ្នែកមួយនៃសំណុំរឿង០០២/០១[49]។ ផ្ទុយទៅវិញលក្ខណៈវិនិច្ឆ័យរបស់អង្គជំនុំជម្រះសាលាដំបូង (ដែលមានបំណងចង់ស្វែងយល់ថាតើកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមដែលបានលើកឡើងពាក់ព័ន្ធយ៉ាងជិតស្និតទៅនឹងការចោទប្រកាន់ផ្នែកអង្គហេតុក្នុងសំណុំរឿង០០២/០១ ដែរ ឬអត់នោះ) គឺអាចយកមកអនុវត្តបានយ៉ាងល្អ។ លើសពីនេះទៅទៀតអង្គជំនុំជម្រះប្រកាន់ភ្ជាប់ឆន្ទានុសិទ្ធិរបស់ខ្លួនបានយ៉ាងល្អនៅពេលអនុវត្តវា[50]។

---

[49] កាលៈទេសៈដែលទង្វើមួយចំនួនត្រូវបានគេបូកបញ្ចូលក្នុងគោលនយោបាយទូទៅតែមួយមិនមែនមានន័យថាអង្គហេតុទាំងនេះពាក់ព័ន្ធគ្នាយ៉ាងជិតស្និតឡើយ។ នេះជាការពិតជាពិសេសនៅពេលដែលគោលនយោបាយមួយត្រូវបានគេបង្កើតឡើងយ៉ាងទូលំទូលាយដែលគោលនយោបាយដែលសហព្រះរាជអាជ្ញាកំពុងពឹងផ្អែកលើ។

[50] ពិតណាស់ ការពិចារណាទាំងនេះមិនបានផ្លាស់ប្តូរការ ពិតដែលបានពិភាក្សាខាងលើដែលថាការសម្លាប់ទាហាន លន់ នល់ មិនមែនជាគោលបំណងសំខាន់មួយក្នុងចំណោមគោលបំណងសំខាន់ទៀតនៃមន្ទីរ ស២១ ហើយម្យ៉ាងវិញទៀត យោងតាមដីកាដំណោះស្រាយមន្ទីរសន្តិសុខដទៃជាច្រើនទៀតក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចោទប្រកាន់ថាបានសម្លាប់ទាហាន លន់ នល់។ ដូច្នេះ មន្ទីរ ស២១ មិនអាចខុសប្លែកពីមន្ទីរសន្តិទាំងនេះដោយសារហេតុផលខាងលើឡើយ។

*ទាហាន លន់ នល់ មិនមានការពាក់ព័ន្ធឡើយ*

៣៣. សហព្រះរាជអាជ្ញាបានសង្កត់ធ្ងន់ជាពិសេសទៅលើការដែលថា "នៅពេលអង្គជំនុំជម្រះសាលាដំបូងលើកឡើងក្នុងសំណុំរឿង០០១ សំខាន់បំផុតជនរងគ្រោះនៅមន្ទីរស២១ រួមមាន "អតីតកម្មាភិបាល និង ទាហាន លន់ នល់" ដែលជាក្រុមគោលដៅពិសេសក្នុងអំឡុងពេលនៃការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងទីសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ"[51]។ ការប្រើពាក្យថា"ជាពិសេស" មានន័យថាសហព្រះរាជអាជ្ញាយល់ឃើញថា ទំនាក់ទំនងរវាងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងមន្ទីរ ស២១ មានការពាក់ព័ន្ធគ្នាជាពិសេស។

៣៤. ទោះបីជាយ៉ាងណាក៏ដោយ វាជាការចាំបាច់ដែលត្រូវលើកឡើងពីលំដាប់លំដោយខាងនីតិវិធីនៃបញ្ហាតាមលក្ខណៈមួយដែលច្បាស់លាស់: **ការអនុវត្ត**នូវគោលនយោបាយដែលកំណត់មុខសញ្ញាវាយប្រហារលើអតីតមន្ត្រីរបបសាធារណៈរដ្ឋខ្មែរ (ដែលការអនុវត្តនេះឃើញកើតមានតែនៅទីកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃប៉ុណ្ណោះ ប៉ុន្តែមិនឃើញកើតមាននៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ[52]) ហើយបានពាក់ព័ន្ធ*ដោយសារតែ* និង*កើតចេញពី*សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការពង្រីកការចោទប្រកាន់ពីបទសម្លាប់ទាហានលន់ នល់ នៅទួលពោធិ៍ជ្រៃតែប៉ុណ្ណោះ[53]។ ឧបសម្ព័ន្ធមានកថាខណ្ឌមួយចំនួនពាក់ព័ន្ធក្នុងសំណុំរឿង០០២/០១ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងថានៅថ្ងៃ១៨ ខែតុលា ឆ្នាំ២០១២ និងមកត្រឹមពេលឥឡូវនេះ ទើបមានការយោងមួយទៅដល់មន្ត្រីរបបសាធារណរដ្ឋខ្មែរ[54]។ ម្យ៉ាងវិញទៀតអាស្រ័យលើ និង*រហូតទល់តែ* មានសេចក្តីសម្រេចដោយអង្គជំនុំជម្រះសាលា

---

[51] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧៤។

[52] ឧបសម្ព័ន្ធ- បញ្ជីកថាខណ្ឌ និងផ្នែកមួយចំនួននៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង០០២/០១, កថាខណ្ឌ១ (vii)។

[53] សំអាងហេតុដទៃទៀតនឹងមានន័យថាអង្គជំនុំជម្រះសាលាដំបូង បានកម្រិតជាស្វ័យប្រវត្តិនូវអំណាចឆន្ទានុសិទ្ធិរបស់ខ្លួនរហូត ដល់កម្រិតមួយដែលខ្លួនបាត់បង់សិទ្ធិ *មិន* ដាក់មន្ទីរ ស២១ ក្នុងបទចោទបន្ថែម ដោយ*ការអនុវត្ត* ឆន្ទានុសិទ្ធិដ៏ទូលំទូលាយរបស់ខ្លួនក្នុងការដាក់បញ្ចូលវាលពិឃាតទួលពោធិ៍ជ្រៃជាប្រធានបទដែលត្រូវពិភាក្សាក្នុងសំណុំរឿង០០២/០១។

[54] ឯកសារ E-124/7.3/corr.2, ឧបសម្ព័ន្ធ-បញ្ជីកថាខណ្ឌ និងផ្នែកមួយចំនួននៃដីកាដំណោះស្រាយដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១, កែតម្រូវបន្ថែមទៀតចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើកាយសម្បទានិងបញ្ញាស្មារតីរបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមសវនាការ (E138), និងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញាសុំ ដាក់

ដំបូងក្នុងការពង្រីកការចោទប្រកាន់ "អង្គហេតុ" ដែលជាប់ពាក់ព័ន្ធនឹងបទចោទថ្មី គ្រាន់តែជាការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងការផ្លាស់ទីលំនៅប្រជាជនទៅដំណាក់កាលទី២*សុទ្ធសាត* ។ វាជាចំណុចចាប់ផ្តើមផ្នែកនីតិវិធីដែលគួរតែបង្កើតបានមូលដ្ឋានដ៏រឹងមាំ សម្រាប់ពិនិត្យបណ្តឹងសាទុក្ខ (ហើយមិនមែនជាស្ថានភាពថ្មី ដែលក្នុងនោះការអនុវត្តពាក់ព័ន្ធនឹងអង្គហេតុនូវគោលនយោបាយមួយចំនួនប្រឆាំងនឹងទាហានលន់ នល់ ត្រូវបានដាក់បញ្ចូលក្នុងក្នុងបទចោទ "ថ្មី"ទាំងនេះ។ បើពិចារណាដល់ចំណុចចាប់ផ្តើមនោះ វាជារឿងសមហេតុផលខ្លាំងណាស់ចំពោះអង្គជំនុំជម្រះសាលាដំបូងក្នុងការសន្និដ្ឋានថាការសម្លាប់នៅស្រុក១២ និងការសម្លាប់នៅមន្ទីរ ស២១ រួមទាំងការសម្លាប់ទាក់ទងនឹងទាហាន លន់ នល់ ផង គឺមិនទាក់ទងជិតស្និតទៅនឹងបទចោទទាក់ទងនឹង*អង្គហេតុ*ដែលមានស្រាប់ដែលមាននៅក្នុងសំណុំរឿង០០២/០១នេះឡើយ។

## ង.ភស្តុតាងពាក់ព័ន្ធនឹងមន្ទីរ ស២១ និងទីតាំងសម្លាប់នៅស្រុក១២ នឹងត្រូវដាក់ឲ្យប្រើ

៣៥. នៅចុងបញ្ចប់សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងអង្គហេតុបន្ថែមទៀត ឬកំហុសក្នុងការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន ដោយខកខានមិនបានពិចារណាស៊ីជម្រៅលើភស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ហើយដែលពាក់ព័ន្ធទៅនឹងមន្ទីរ ស២១ និងទីតាំងសម្លាប់ស្រុក១២។ យោងតាមសហព្រះរាជអាជ្ញា ការខកខានមិនបានប្រើប្រាស់ភស្តុតាងទាំងនេះ គឺ"ផ្ទុយទៅនឹងផលប្រយោជន៍យុត្តិធម៌ និងការគ្រប់គ្រងជំនុំជម្រះដ៏ល្អ"។ ទឡ្ហីករណ៍នេះមិនគួរឲ្យជឿឡើយ។ ពិតណាស់ ប្រសិនបើមានភស្តុតាងដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធទៅនឹងមន្ទីរស២១ និងទីតាំងសម្រាប់នៅស្រុក១២ វាគ្មានហេតុអ្វីដែលត្រូវសន្និដ្ឋានថាភស្តុតាងនេះនឹងមិនត្រូវយកមកប្រើឡើយ ទោះបីជាកិច្ចដំណើរការនីតិវិធីនឹងមិនបន្តបន្ទាប់ពីសំណុំរឿង០០២/០១ក៏ដោយ។ បន្ទាប់មកភស្តុតាងបែបនេះនឹងត្រូវអង្គជំនុំជម្រះយកមកប្រើដើម្បីចេញសេចក្តីសម្រេចមួយក្នុងគោលបំណងវាយតម្លៃ "សាច់រឿងគ្រប់ជ្រុងជ្រោយជាច្រើនក្នុងសំណុំរឿង០០២ រួមទាំងប្រវត្តិសាស្ត្រ រចនាសម្ព័ន្ធនៃអំណាច និងការទំនាក់ទំនងរបស់បក្សកុម្មុយនីស្តកម្ពុជា និងរបបកម្ពុជាប្រជា

---

បញ្ចូលកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មបន្ថែមទៀតទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ (E163)-ឯកសារដែលបានកែតម្រូវ, ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២, ERN 0854112-00854115, ទំព័រទី១។

ធិបតេយ្យ តួនាទី និងមុខតំណែងរបស់ជនជាប់ចោទ ក៏ដូចជាការបង្កើតផែនការឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ក្នុងដីកាដំណោះស្រាយ[55]”។ ដូច្នេះ ទោះជាបែបណា ក៏ដោយភស្តុតាងនេះនឹងមិនបាត់បង់ឡើយ។

## V.សេចក្តីសន្និដ្ឋាន

៣៦. ដូច្នេះ អាស្រ័យលើហេតុផលដែលបានគូសបញ្ជាក់ក្នុងចម្លើយតបនេះ អង្គជំនុំជម្រះតុលាការកំពូលគប្បី (i) ប្រកាសថា បណ្តឹងសាទុក្ខភ្លាមៗនេះមិនអាចទទួលយកបាន ឬ (ii)ច្រានចោលបណ្តឹងសាទុក្ខភ្លាមៗនេះ និង (iii) យល់ព្រមលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។

**សហមេធាវីការពារក្តីលោក នួន ជា**

Jasper PAUW

Michiel PESTMAN

[55] បណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ៧០។